# គណបក្ស សិទ្ធិមនុស្ស

HUMAN RIGHTS PARTY

លេខ ០៦៣៣/១១ គ.ស.ម

បំរើ ការពារ កសាង


## ប្រធានគណបក្សសិទ្ធិមនុស្ស

## សូមគោរពជូន

**លោកស្រី តូច ឆៃហ៊ាន់** ដែលត្រូវជាភរិយាលោក ផាន ផា ព្រមទាំងក្រុមគ្រួសារ

**លោកស្រី ឆៀប ស៊ីលន់** ដែលត្រូវជាភរិយាលោក ភូមិ យាន ព្រមទាំងក្រុមគ្រួសារ

លោកស្រី ព្រមទាំងក្រុមគ្រួសារជាទីគោរពរាប់អានដ៏ស្មោះ !

បន្ទាប់ពីខ្ញុំ និងថ្នាក់ដឹកនាំជាន់ខ្ពស់របស់គណបក្សសិទ្ធិមនុស្ស បានទទួលដំណឹង និងបានឃើញផ្ទាល់ នូវអំពើអយុត្តិធម៌ដោយការគម្រាមកំហែងរហូតដល់ចាប់ឃុំខ្លួន លោក ផាន ផា និងលោក ភូមិ យាន ដោយពួកអ្នកកាន់អំណាច កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១១នោះមក ។ ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស ទាំងអស់គ្នាមានការខ្វាយខ្វល់យ៉ាងខ្លាំង ហើយបាននឹងកំពុងជួបជុំគ្នាជាបន្តបន្ទាប់ ធ្វើសកម្មភាពនានាដើម្បីតវ៉ាទាមទារឲ្យលោកទាំងពីរទទួលបានការដោះលែង និងមានសេរីភាពឲ្យបានឆាប់រហ័ស ។

គណបក្សសិទ្ធិមនុស្ស ចាត់ទុកលោក ផាន ផា និងលោក ភូមិ យាន ថាជាអ្នកស្នេហាជាតិខ្មែរ ជាអ្នកស្រឡាញ់លទ្ធិប្រជាធិបតេយ្យដ៏អង់អាចក្លាហាន ហ៊ានលះបង់មិនខ្លាចនឿយហត់ ដើម្បីផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋខ្មែរចូលរួមយ៉ាងសកម្ម ដោយស្មោះជាមួយគណបក្សសិទ្ធិមនុស្ស ។ លោកទាំងពីរខាងលើមិនដែលបានធ្វើអ្វីខុសនឹងច្បាប់រដ្ឋឲ្យប៉ះពាល់ដល់ផលប្រយោជន៍ជាតិ ផលប្រយោជន៍សង្គម និងផលប្រយោជន៍ប្រជាពលរដ្ឋខ្មែរឡើយ ។

ដូច្នេះក្នុងនាមគណបក្សសិទ្ធិមនុស្ស និងក្នុងនាមខ្ញុំផ្ទាល់ ក៏ដូចជាថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សដ៏ទៃទៀតដែរ ខ្ញុំសូមលោកស្រី ព្រមទាំងក្រុមគ្រួសារពង្រឹងស្មារតីឲ្យបានរឹងមាំ កុំតក់ស្លុត យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំសកម្មជន ជាយុទ្ធមិត្តក្នុងគណបក្សសិទ្ធិមនុស្សទាំងអស់ ចូលរួមសុខទុក្ខនៅជាមួយលោកស្រី ព្រមទាំងក្រុមគ្រួសារជានិច្ច មិនបំភ្លេចឡើយ ។

ខ្ញុំផ្ទាល់ និងថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស និងខិតខំធ្វើប្រតិកម្មទាមទារ តវ៉ា តាមផ្លូវច្បាប់ តាមការទូត និងតាមសកម្មភាពនានាទាំងក្នុង និងក្រៅប្រទេសឥតឈប់ទេ រហូតដល់មានការដោះលែងលោកទាំងពីរឲ្យមានសេរីភាព ។ រាល់ការតវ៉ាទាមទារ ការចំណាយនានា ដូចជាការចំណាយលើមេធាវី ចំណីអាហារ សម្ភារៈចាំបាច់សម្រាប់លោកទាំងពីរក្នុងការដោះស្រាយបញ្ហានេះ គណបក្សសិទ្ធិមនុស្សជាអ្នកទទួលខុសត្រូវក្នុងការចំណាយ ។

សូមជូនពរលោកស្រី ព្រមទាំងក្រុមគ្រួសារ ទទួលនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមលោកស្រី និងក្រុមគ្រួសារ ទទួលនូវការគោរព និងរាប់អានអំពីខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១១

ជ.សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្សសិទ្ធិមនុស្ស

**ប្រធានគណបក្ស**

HUMAN RIGHTS PARTY

**កឹម សុខា**


Address: #72-74, Street 598, Sangkat Boeung Kok 2, Khan Tuol Kok, Phnom Penh, Cambodia.

Tel: (+855) 17 303 900 - http://www.hrpcambodia.info - hrpcambodia@yahoo.com